# ការសម្ពោធដាក់ឲ្យដំណើរការ មូលនិធិសហគ្រាសសង្គម

PSI/CAMBODIA'S



## សេចក្តីផ្តើម

ចាប់ដំណើរការក្នុងឆ្នាំ ២០១៧ មូលនិធិសហគ្រាស (EF), អង្គការ ភី អេស អាយ បានអនុវត្តគោលការណ៍ពាណិជ្ជកម្មក្នុងការបង្កើតការផ្គត់ផ្គង់ទំនិញប្រកបដោយនិរន្តរភាព និងផ្តល់ផលប៉ះពាល់សុខភាពប្រកបដោយនិរន្តរភាព។ ទោះបីជាមូលនិធិសហគ្រាសត្រូវបានបង្កើតឡើងជាផ្លូវការក្នុងឆ្នាំ ២០១៧ ការផ្លាស់ប្តូរពីអ្នកឧបត្ថម្ភទាំងស្រុងទៅជាគំរូអាជីវកម្មដែលទ្រទ្រង់ដោយខ្លួនឯង គឺជាដំណើរការដ៏លំបាកមួយដែលវិវត្តន៍ជាងមួយទសវត្សមកហើយ។ ក្នុងអំឡុងពេលដែលនិន្នាការម្ចាស់ជំនួយឈប់ផ្តល់អោយផលិតផលសុខភាព គឺចាំបាច់ណាស់ត្រូវតែបង្កើតឡើងនូវទីផ្សារ នៅនឹងកន្លែងមួយដែលមាននូវស្ថេរភាព និងនិរន្តរភាព ដើម្បីធានានូវការរកប្រើប្រាស់បាននូវផលិតផលសុខភាព។ កន្លងមកតាមរយៈជំនួយ អង្គការ ភី អេស អាយ អាចកំណត់តម្លៃបានច្បាស់ និងធ្វើការផ្សព្វផ្សាយពីផលិតផលរបស់ខ្លួន បង្កើតស្ថេរភាព ទីផ្សារសុខភាព និងជាបណ្តើរៗតម្រូវការពីការទទួលជំនួយត្រូវបានកាត់បន្ថយ។ ប្រាក់ចំណូលប្រតិបត្តិការរបស់មូលនិធិសហគ្រាស មានចំនួន ១.៣ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៨ និង១.៥ លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៩។ នៅឆ្នាំ ២០២០ មូលនិធិសហគ្រាសបានប្រតិបត្តិទូទាំង២៥ខេត្ត/ក្រុង នៅក្នុងប្រទេសកម្ពុជា ដែលមានផលិតផលផ្សេងៗគ្នាដូចជា ថ្នាំរំលូតកូន កងដាក់ក្នុងស្បូន កងដាក់ក្រោមស្បែក ថ្នាំគ្រាប់ពន្យារកំណើតបន្ទាន់ ថ្នាំគ្រាប់ពន្យារកំណើត ស្រោមអនាម័យ និងថ្នាំការពារបាត់បង់ជាតិទឹក។

## គម្រោងសុខភាពស្ត្រី

គម្រោងសុខភាពស្ត្រីគឺជាគម្រោងសកលដែលអនុវត្តឡើងដើម្បីពង្រីកលទ្ធភាពក្នុងការទទួលបានការរំលូតកូនប្រកបដោយសុវត្ថិភាព និងការពន្យារកំណើតរយៈពេលវែង រួមបញ្ចូលទាំងការពន្យារកំណើតបន្ទាប់ពីការរំលូតកូនដែល អង្គការ ភី អេស អាយ បានអនុវត្តចន្លោះឆ្នាំ ២០០៨ – ២០២០។ បើពុំមានម្ចាស់ជំនួយ ក្នុងការចំណាយនៅពេលចាប់ផ្តើម និងការគាំទ្រលើការបង្កើតទីផ្សារជាបន្តបន្ទាប់ទេនោះ ការប្តូរទិសដៅពីមូលនិធិទៅជាសហគ្រាសសង្គមដែលទ្រទ្រង់ដោយខ្លួនឯង នឹងមិនអាចកើតឡើងបានឡើយ។ ចន្លោះឆ្នាំ ២០១០ និង ២០១៨ ការលក់ថ្នាំមេដាបូន (ថ្នាំរំលូតកូន) កងដាក់ក្នុងស្បូន និងកងដាក់ក្រោមស្បែក ត្រូវបានទទួលជំនួយពីគម្រោងសុខភាពស្ត្រី ហើយបន្ទាប់មកទីផ្សារដែលមានជំនួយនោះ ត្រូវបានកាត់បន្ថយបន្តិចម្តងៗ។ នៅក្នុងឆ្នាំ២០២០ ផលិតផលរបស់គម្រោងសុខភាពស្ត្រីទាំងអស់ត្រូវបានបញ្ចូលទៅក្នុងផលិតផលមូលនិធិ សហគ្រាស និងបន្តចែក ចាយទៅកាន់ស្ត្រីទូទាំងប្រទេសកម្ពុជា ទោះបីជាជំនួយនោះត្រូវបានបញ្ចប់ហើយក៏ដោយ។

# ការទទួលបានថ្លៃដើម

ជំនួយពីគម្រោងសុខភាពស្ត្រី គឺពិតជាសំខាន់ណាស់ ដើម្បីគាំទ្រការផ្លាស់ប្តូរមូលនិធិសហគ្រាសពីការទទួលបានជំនួយសុទ្ធសាធទៅជាគំរូអាជីវកម្មដែលទ្រទ្រង់ដោយខ្លួនឯងប្រកបដោយស្ថេរភាព។ លើកលែងតែ ម៉ាយហ្វីសូរ (Mifeso) ផលិតផលគម្រោងសុខភាពស្ត្រីទាំងអស់បានចាប់ផ្តើម ដំបូងដោយទទួលបានជំនួយ រួចត្រូវបានផ្លាស់ប្តូរទៅលក់នៅក្នុងថ្លៃដើម (COGs១) និងក្រោយមកបន្តឈានទៅលក់ដោយមានប្រាក់ចំណេញ។ នៅពេលដែលផលិតផលនីមួយៗទទួលបានលើសថ្លៃដើមមកវិញហើយ ប្រាក់ចំណេញ២ ត្រូវបានប្រើសម្រាប់ផ្គត់ផ្គង់ថ្លៃប្រតិបត្តិការសំខាន់ៗ រួមបញ្ចូលទាំងក្រុមធ្វើទីផ្សារ ប្រាក់ខែ និងការបណ្តុះបណ្តាលបុគ្គលិកផ្នែកលក់ ឃ្លាំងស្តុកទំនិញ និងការចែកចាយ និងថ្លៃរដ្ឋបាលទូទៅផ្សេងៗទៀត។ ផលិតផលទាំងអស់ដែលត្រូវបានគ្រប់គ្រងដោយមូលនិធិសហគ្រាសទទួលបានប្រាក់ចំណេញសុទ្ធ ជាហេតុដែលនាំឲ្យមានការធានាស្ថេរភាពដល់ការផ្គត់ផ្គង់ផលិតផលសម្រាប់ស្ត្រីទូទាំងប្រទេសកម្ពុជា។ ក្រៅពីនេះប្រាក់ចំណេញក៏បានប្រើប្រាស់សម្រាប់គាំទ្រ ដល់សកម្មភាពផ្សេងៗទៀត ដែលពីមុនធ្លាប់គាំទ្រដោយមូលនិធិគម្រោង។ កម្មវិធីទាំងនោះរួមមានបណ្តាញទូរស័ព្ទសុខភាពស្ត្រី និងការគ្រប់គ្រងព្រឹត្តិការណ៍អាក្រក់អាចបន្តដល់ឆ្នាំ ២០២១ ឬអាចក្រោយឆ្នាំ ២០២១។

## ការបង្កើតនិរន្តរភាពទីផ្សារសម្រាប់ថ្នាំរំលូតកូន

ចាប់ពីការនាំចូល និងចែកចាយផលិតផលថ្នាំរំលូតកូនមេដាបូនដែលបានចុះបញ្ជីដំបូងគេបង្អស់ក្នុងប្រទេសកម្ពុជា រហូតដល់មានការបណ្តុះបណ្តាលអ្នកផ្គត់ផ្គង់ជាច្រើន និងការជួយបង្កើនការយល់ដឹងអំពីសេវារំលូតកូនដោយសុវត្ថិភាពតាមរយៈការប្រាស្រ័យទាក់ទងផ្ទាល់អង្គការ ភី អេស អាយ គឺជាចំនុចសំខាន់ក្នុងការបង្កើតស្ថេរភាពទីផ្សារ ថ្នាំរំលូតកូននៅក្នុងប្រទេសកម្ពុជា។

នៅក្នុងឆ្នាំ២០១០ អង្គការ ភី អេស អាយ បានធ្វើការណែនាំថ្នាំមេដាបូន នៅតម្លៃដែលទទួលបានជំនួយ ដើម្បីធានាដល់អត្រាចំនេញសម្រាប់អ្នកលក់ដុំសម្រាប់ថ្នាំមេដាបូនអាចប្រកួតប្រជែងជាមួយនឹងថ្នាំរំលូតកូនផ្សេងទៀតដែលមិនបានចុះបញ្ជី ហើយមានគុណភាពទាបនៅលើទីផ្សារ។ ថ្នាំមេដាបូន ទទួលបានកំណើននៃការលក់ពីមួយឆ្នាំទៅមួយឆ្នាំដោយធានាតម្លៃសមរម្យដែលប្រជាជនអាចទទួលយកបាន។

នៅក្នុងឆ្នាំ ២០១៨ អង្គការ ភី អេស អាយ បានបន្តពង្រីកជម្រើសដល់អ្នកប្រើប្រាស់ ជាមួយនឹងការចាប់ផ្តើមនៃថ្នាំរំលូតកូនប្រភេទទី២ ដែលមានឈ្មោះថា ម៉ាយហ្វេសូ Mifeso។ ស្ថិតនៅក្រោមគម្រោងសុខភាពស្ត្រីនៃអង្គការ ភី អេស អាយ

- បានបង្កើនការចែកចាយផលិតផលរំលូតកូនដោយសុវត្ថិភាព អង្គការ ភី អេស អាយ បានចែកចាយថ្នាំរំលូតកូនជាង ២,១០៦,០០០ដូស ត្រឹម ខែធ្នូ ឆ្នាំ២០១៩ សាខាចែកចាយចំនួន ២,៨៨៤ កន្លែង មានស្តុកថ្នាំរំលូតកូនដែលគ្រប់ដណ្តប់ស្រុកចំនួន៩៤% ក្នុងប្រទេសកម្ពុជា។
- ធ្វើអោយប្រសើរឡើងនូវការផ្តល់សេវាសុខភាពឯកជនតាមរយៈការបណ្តុះបណ្តាល និងបន្តចុះសួរសុខទុក្ខអ្នកផ្តល់សេវាសុខភាពនានា។ បណ្តាញអ្នកផ្តល់សេវាជាង ២៥០នាក់ បានទទួលការបណ្តុះបណ្តាលទាក់ទងនឹងជម្រើសក្នុងការមានផ្ទៃពោះ និងការចុះសួរសុខទុក្ខជាទៀតទាត់ (៣-៤ដងក្នុងមួយឆ្នាំ)។ លើសពីនេះទៀត បណ្តាញអ្នកផ្តល់សេវាជាង ២,១៥០នាក់ផ្សេងទៀតក៏បានទទួលការបណ្តុះបណ្តាលអំពីការផ្លាស់ប្តូរឥរិយាបថការប្រាស្រ័យទាក់ទងផងដែរ។

## សូមអរគុណ

គម្រោងសុខភាពស្ត្រីបានកើតឡើងតាមរយៈជំនួយសប្បុរសធម៌ និងការចូលរួមសហការពីរាជរដ្ឋាភិបាលកម្ពុជា និងអ្នកដែលជាប់ពាក់ព័ន្ធផ្សេងៗទៀត។ អង្គការ ភី អេស អាយ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូរក្នុងស្រុកផ្សេងទៀតដែលបានសហការអស់រយៈពេលជាងមួយទសវត្សរ៍ និងបានបញ្ចប់ការសហការ។ អង្គការ ភី អេស អាយ ក៏សូមថ្លែងអំណរគុណដល់អ្នកទាំងអស់គ្នានៅក្នុងបណ្តាញបន្ទប់ ពិគ្រោះព្យាបាលសញ្ញាព្រះអាទិត្យដែលបានប្តេជ្ញាចិត្តក្នុងការផ្តល់សេវាប្រកបដោយគុណភាពខ្ពស់ និងធ្វើអោយ ប្រសើរឡើងនូវសុខភាពស្ត្រីកម្ពុជា។ ជាចុងក្រោយ ក៏សូមថ្លែងអំណរគុណដល់ក្រុមការងារ ភី អេស អាយ ទាំងមូល ដែលបានជួយជ្រោមជ្រែងផ្នែកបច្ចេកទេសដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន។

### សម្រាប់ព័ត៌មានបន្ថែម សូមធ្វើការទាក់ទងមកកាន់

វេជ្ជ. ហេងខេង
នាយក សុខភាពបន្តពូជ និងផ្លូវភេទ
kheng@psi.org.kh

SHIRINE MOHAGHEGHPOUR
ទីប្រឹក្សាបច្ចេកទេសជាន់ខ្ពស់សេវាកម្មដឹកជញ្ជូន
smohagheghpour@psi.org

[1] COGs Cost Recovery: all direct costs attributable to the production of goods sold, including the cost of production, packaging, and all fees associated with shipping and handling.
[2] Gross Margin: net sales minus the COGS.